D24859
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ ប្រាក់ ខន

## អតីតយុទ្ធជនសួរចម្លើយនៅស-២១

## នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២

## នៅគុកទួលស្លែង (លើកទី២)

## ដោយ ហ៊ុយ វណ្ណៈ

វណ្ណៈ ខ្ញុំសួរពីអារម្មណ៍របស់ពូដែលពូធ្លាប់ធ្វើការនៅស-២១ ហើយនៅពេលដែលពូបានត្រឡប់មកឃើញកន្លែងដែលពូធ្លាប់ធ្វើអញ្ចឹង តើពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ខន ពេលដែលខ្ញុំចូលមកដល់កន្លែងនេះវិញ ខ្ញុំមានរម្មណ៍រន្ធត់ចិត្តចំពោះរឿងរ៉ាវកាលពីមុន ពីព្រោះថា កន្លែងនេះជាកន្លែងសោកនាដកម្ម ។ ខ្ញុំមានការអៀនខ្មាសខ្លួននៅកន្លែងហ្នឹង ។

វណ្ណៈ ពូអៀនខ្មាសយ៉ាងម៉េច?

ខន អារម្មណ៍មានការអៀនខ្មាស ដែលបានធ្វើទង្វើទាំងអស់នោះដែលគេហៅថាឃោរឃៅពីមុនមក ហើយមកលាតត្រដាងខ្ញុំមានការអៀនខ្មាសខ្លួនជាមួយអ្នកដទៃ ។

វណ្ណៈ តាំងពីពូឈប់ធ្វើការនៅកន្លែងនេះតាំងពីឆ្នាំ១៩៧៩ ពូមានដែលខ្វល់ខ្វាយ ឬក៏គិតយ៉ាងម៉េចចំពោះខ្លួនពូ រហូតមកដល់ពេលនេះ?

ខន ទេ! កាលនោះខ្ញុំគ្មានការគិតគូរអ៊ីវែងឆ្ងាយទេ ដោយសារព្រួសូរបក្សនិងរដ្ឋលើកឡើងថាលើកលែងសណ្ដោសទោសកាលពីមុន មិនដាក់ទោសកំហុសទៅលើអ្នកណាម្នាក់ ។ ដល់ចឹងអារម្មណ៍វាគ្មានគិតគូរពីបញ្ហាអីទេ គឺថាជំនាន់នោះកាលដែលខ្ញុំធ្វើការនៅសម័យរដ្ឋកម្ពុជាគឺគិតគូរតែពីការងារ ។

វណ្ណៈ ចាប់តាំងពីពូឈប់ធ្វើការងារនៅមន្ទីរស-២១ មានអ្នកណាធ្លាប់ស្គាល់ពីប្រវត្តិរបស់ពូទេ?

ខន អត់មានទេ ។

វណ្ណៈ ពូមានដែលនិយាយពីរឿងហ្នឹងប្រាប់អ្នកណាដែរ?

ខន អត់ដែលសោះ ។

វណ្ណៈ រហូតដល់ពេលណាទើបមានការដឹងពីប្រវត្តិរបស់ពូ?

ខន ប្រហែលជាឆ្នាំ១៩៩៧ សូរីយ៉ា និង ខស្មាន ទៅរកឃើញទើបដឹងតាំងពីពេលហ្នឹងមក ។

វណ្ណៈ នៅពេលដែលមានអ្នកស្រាវជ្រាវទៅជួប ពូមានគិតថា យ៉ាងម៉េចដែរ?

ខន ខ្ញុំអត់មានព្រកែកប្រណាំងទេ ពេលដែលសួរ ខ្ញុំរាយរ៉ាប់ប្រាប់ទាំងអស់ ។

វណ្ណៈ ជាចិត្តរបស់ពូ តើពូប្រាប់ហ្នឹងដើម្បីអ្វីដែរ?

ខន ចិត្តខ្ញុំកាលហ្នឹង ខ្ញុំចង់ប្រាប់ដើម្បីលុបលាងពីទោសកំហុសដែលខ្លួនបានធ្វើឲ្យគេដឹងថាជំនាន់ហ្នឹងយ៉ាងម៉េច ។

វណ្ណៈ ខ្ញុំគិតថា ពេលដែលពូនិយាយ គឺលេនោះរដ្ឋាភិបាលមានរៀបចំច្បាប់មួយ ពេលហ្នឹងពូគិតយ៉ាងម៉េចដែរ?

ខន ពេលដែលពូសួរថា មានការកាត់ទោស ខ្ញុំមានចិត្តព្រួយបារម្ភណ៍ ប៉ុន្តែដំណាក់កាលនេះខ្ញុំលែងគិតអីហើយ វាទៅយ៉ាងម៉េចក៏ទៅៗ ។ បើថា អង្គការគិតថា អ្នកតូចអ្នកតាចក្រោមអំណាចគេ គេប្រើឲ្យធ្វើខ្ញុំចេះតែធ្វើ ពីព្រោះថា ក្រោមរបបនោះយើងនៅក្រោមការកៀបសង្កត់របស់គេ កាលណាយើងមិនធ្វើ នោះរឹតតែស្លាប់ឆាប់ជាងយើងដែលមិនធ្វើតាមគេទៅទៀត ។

វណ្ណៈ ពេលដែលពូធ្វើការនៅសម័យខ្មែរក្រហម ពូធ្លាប់បានជួប ពូឌី ពូហ៊ុយ និងពូហួ ដែរ?

ខន ជួបគ្នាដែរ ពីព្រោះកាលពីមុនជាមនុស្សដែលធ្លាប់នៅកងជាមួយគ្នា ។ កាលនៅកងមុនពេលចូលមកនៅកន្លែងនេះ(ស-២១) ខ្ញុំធ្លាប់និយាយលេងសើចទៅមក ។ ប៉ុន្តែពេលចូលមកដល់កន្លែងនេះ គ្រាន់តែឃើញ គ្រាន់តែស្គាល់ ប៉ុន្តែមិនដែលនិយាយគ្នា ឬ សួរគ្នាឯងនៅឯណា? ធ្វើអីនៅឯណា អត់មានទេ គ្រាន់តែដឹងថាយាម ឬ ធ្វើអ្វីមួយ មិនអាចនិយាយគ្នាបានឡើយ ហើយមករបៀបម៉េច អ្នកណាបញ្ជូនមក មិនដឹងទេ ។

វណ្ណៈ ជាវិន័យគេកំណត់មកឬក៏យ៉ាងម៉េច?

ខន អាហ្នឹងជាវិន័យដែលគេកំណត់មក គេថា បើនៅកន្លែងសួរឲ្យដឹងសួរ បើនៅកន្លែងការពារឲ្យដឹងការពារ អត់មានឲ្យនិយាយពីរឿងសួរទៅប្រាប់ការពារ និយាយរឿងការពារមកប្រាប់ខាងសួរមិនបានទេ អ្នកណានៅកន្លែងណានៅកន្លែងហ្នឹង ។

វណ្ណៈ ប៉ុន្តែក្នុងចិត្តពូចង់សួរដែរ ឬក៏យ៉ាងម៉េច?

ខន	ក្នុងចិត្តចេះតែមានហើយ ពីព្រោះធ្លាប់ឃើញ ធ្លាប់ស្គាល់គ្នា ចេះតែចង់សាកសួរគ្នា ។ ប៉ុន្តែនឹកឃើញថា បើសួរត្រូវគេចាប់ ត្រូវគេចោទប្រកាន់ថាយើងទាក់ទងខុសលក្ខណ៍ការណ៍របស់គេ ។ ចឹងចិត្តមួយថា មិនរវល់ទេ អ្នកណាធ្វើអីក៏ធ្វើទៅ ធ្វើយ៉ាងម៉េចឲ្យតែបាមសុខឲ្យបានរួចខ្លួន ព្រោះអ្នកសួរនៅកន្លែងខ្ញុំ២០,៣០នាក់ចាប់អស់ហើយ នៅតែខ្ញុំម្នាក់ ។

វណ្ណៈ	ចាប់ពីពេលណា ដែលមានការចាប់ខ្លួនរបៀបណឹង?

ខន	ចាប់ពី៧៧,៧៨ គឺចាប់ជាបន្តបន្ទាប់ ពិសេសកម្លាំងមកពីតំបន់៣១ ខាងភូមិភាគបស្ចឹម ពីព្រោះខាងកម្លាំង៣១ ក្នុងជាមួយខាង៧០៣ ។

វណ្ណៈ	មានបញ្ហាក្នុងយ៉ាងម៉េចពូ?

ខន	ខ្ញុំមិនបានដឹងដល់លើទេ ។ រឿងក្នុងគ្នា ដោយនៅក្នុងស-២១ត្រូវចាប់មេកងពល៧០៣ របស់ភូមិភាគពិសេស ដល់តែចាប់មេ ចេះតែស្រាវជ្រាវចាប់ជាបន្តបន្ទាប់ ។ ដល់ចឹងកម្លាំងដែលយកមកគុកទួលស្លែងមុនដំបូងគឺ៧០៣ដែលយកមកប្រើប្រាស់នៅណឹង ។ ដល់តែស្រាវជ្រាវចាប់មេៗជាបន្តបន្ទាប់រហូតដល់ចាប់កូនចៅតូចតាច ចឹងត្រូវយកកម្លាំងរបស់ភូមិភាគបស្ចឹមយកមកដាក់វិញ ។ ពេលដែលដាក់ភូមិភាគបស្ចឹម ក៏ចាប់ផ្ដើមបោសសម្អាតកម្លាំង៧០៣នៅក្នុងណឹងទាំងអស់ ។

វណ្ណៈ	យ៉ាងបានជាដាក់បស្ចឹម ហើយបោសសម្អាត៧០៣?

ខន	អាណឹងគេថាខាងភូមិភាគពិសេស ៧០៣ ក្បត់ ។ គេយកខាងភូមិភាគបស្ចឹម កុមារៗមកដាក់ ដែលគេហៅថាអ្នកល្អបរិសុទ្ធ អ្នកពេញសិទ្ធិ ។

វណ្ណៈ	ពូគិតថា ការចាប់ខ្លួនមនុស្សអតីតយ៧០៣ធ្វើការនៅស-២១ ដោយសារអីដែរ?

ខន	អាណឹងដោយសារគេចាប់មេយកមក ចេះតែឆ្លើយពេលធ្វើទារុណកម្ម ឈឺ ចេះតែឆ្លើយដាក់ជាខ្សែបណ្ដាញបន្តបន្ទាប់ ។ ឧទាហរណ៍ខ្ញុំនៅក្នុងកងមួយ គេចាប់មេកងមួយ មេកងឆ្លើយដាក់ម៉ោខ្ញុំប្រធានក្រុម ប្រធានពួកតទៅមកទៀត ។ ដល់ចឹងបើមិនឆ្លើយថាជាប្រធានក្រុម ក៏ឆ្លើយដាក់ជាខ្សែបណ្ដាញសេ.អ៊ី.អា ឬក៏ជាខ្សែអីផ្សេង ។ ដល់ចឹងគេចេះតែស្រាវជ្រាវចាប់តាមណឹង ។

វណ្ណៈ	ពេលមានការចាប់ខ្លួនចឹង ពូមានធ្លាប់អតីតជា៧០៣ ពូគិតយ៉ាងម៉េចដែរ?

ខន	កាលណឹងខ្ញុំព្រួយបារម្ភខ្លាំងណាស់ ក្នុងសម័យឥឡូវខ្ញុំអត់សូវបារម្ភទេ ការបារម្ភមាបនគិច

ទេ ។ កាលសម័យនោះ ខ្ញុំភ័យញ័រខ្លួនទាំងអស់ ភ័យលើសអ្វីៗទាំងអស់ ខ្ញុំមិនដែលជួបទេក្នុងពេលធ្វើសង្គ្រាម ប៉ុន្មានឆ្នាំក៏ខ្ញុំមិនដែលភ័យ ។ ពេលមានចាប់នៅក្នុងណឹងគឺ មើលទៅអស់ក្រឡាអាលឹង មិនដឹងចេញទៅច្រកណា ដល់ចឹងមួយយប់ៗដេកញាក់ អត់ទាន់មានអ្នកណាធ្វើអីខ្ញុំទេ គ្រាន់តែឃើញសភាពការណ៍ខាងក្រៅដេកញាក់ ភ័យខ្លួន នឹកឃើញថាអញមិនដឹងជាថ្ងៃណា រង់ចាំតែថ្ងៃ ព្រោះវាអស់ទៅហើយ ។

វណ្ណៈ ក្នុងពេលដែលអារម្មណ៍របស់ពូភ័យ ការឆ្លើយសួររបស់ពូវិវត្តន៍យ៉ាងម៉េចដែរ?

ខន ការឆ្លើយចេះតែធ្វើធម្មតា ប៉ុន្តែអារម្មណ៍មួយសួរ អារម្មណ៍មួយគិតគ្រប់ច្រកល្ហកទាំងអស់ គិតពីរឿងខ្លាចគេចាប់ ។ អីចឹងចេះតែលៃ កុំធ្វើអីនាំឲ្យគេចាប់អារម្មណ៍ ការនិយាយស្តី ការទាក់ទង កាត់ផ្តាច់ទាំងអស់ ។

វណ្ណៈ ក្នុងវិធីសាស្ត្រសួរចម្លើយអ្នកទោស ពូគិតថា ចម្លើយដែលឆ្លើយមកពិតទាំងអស់ ឬក៏មានចំណុចណាខ្លះដែលមិនពិត?

ខន ខ្លះក៏មានដែរ ប៉ុន្តែក្នុង១០០មាន៨,៥ដែលគេថា រឿងពិតដូចជា ខ្សែសេ.អ៊ី.អា អាណឹងមាន ប៉ុន្តែខុសពីណឹងវាមិនអាចពិត ពីព្រោះជួនកាលវាយខ្លាំង ក៏ចេះតែឆ្លើយ ចេះតែប្រាប់ថា អ្នែងខ្សែនេះខ្សែនោះឲ្យវាឆ្លើយ ។

វណ្ណៈ ចឹងពេលដែលពូសួរ ពូប្រាប់អ្នកទោសឲ្យឆ្លើយ ឬក៏យ៉ាងម៉េច?

ខន អាណឹងគេយកឯកសារមុនៗយកមកឲ្យមើល ប្រាប់ឈ្មោះអ្នកនេះៗជាមេ ។ ដល់ចឹងយូរទៅ ពេលដែលអាចយល់អាចដឹងចេះតែឆ្លើយរួមផ្សំ ។

វណ្ណៈ វិធីសួរដំបូង អ្នកទោសត្រូវឲ្យអានចម្លើយរបស់អ្នកចាស់ឬក៏យ៉ាងម៉េច?

ខន មិនឲ្យអានទេ សួរពីប្រវត្តិការរស់នៅជាមួយកងណាក្រុមណា ហើយបានចាប់សួរ ហើយចុះមេអ្នែងគេចាប់យកម៉ោហើយ? ដល់ចឹងវាអាចយល់ពីគំនិតដែលយើងចង់សួរ ។ ដល់ពេលចាប់ម៉ោចឹង យើងប្រាប់ថា មេអ្នែងបានឆ្លើយដាក់ហើយ ។ ដល់ចឹងមនុស្សដឹងខ្លួនហើយ ។ អីចឹង កម្លាំងបដិវត្តន៍ដែលធ្លាប់រស់នៅជាមួយគ្នាមកកាឡៃធ្វើជាពាក្យខ្សែក្បត់សកម្មភាពក្បត់ទៅវិញ ។

វណ្ណៈ សម្រាប់ពូយល់ថា កាពិតមានតិច ក្នុង១០០មានពិតតែ៨,៥ទេ ។ ពូដឹងថា មិនពិតដែរចុះពេលយករបាយការណ៍ទៅថ្នាក់លើ គេមានគិតថាយ៉ាងម៉េចទៀតដែរ?

ខន ខ្ញុំរាយការណ៍ទៅតាមការសរសេរ តាមគំនិតរបស់យើង ។ ការយកទៅនោះមិនកត់ត្រាទេ មិនសិនណាគេជឿ គេមិនប្រគល់ត្រឡប់មកវិញទេ ប៉ុន្តែបើគេមិនជឿ គេគូសវាសមកវិញ ។ ចឹងក្នុងចម្លើយមួយៗមាន៤,៥សារ ឬក៏១០,២០សារ ចេះតែបញ្ជូនមក មានខ្លះដល់ ១០០សារក៏មានដែរ ។

វណ្ណៈ ចម្លើយដែលបានមក ពួយកទៅឲ្យអ្នកណាដែរ?

ខន ឲ្យតាចាន់ ហើយ ឌុច ។ ដំបូងឡើយខ្ញុំយកទៅឲ្យចាន់ បើយល់ព្រមឬមិនយល់ព្រមគេចារ ឲ្យសួរ នៅត្រង់នេះទៀតៗ ខ្ញុំត្រូវធ្វើសារថ្មីឲ្យគេទៀត ។

វណ្ណៈ អ្នកទោសដែលបន្ទាប់ពីសួរហើយយកទៅណា?

ខន សួរហើយយកមកដាក់នៅក្នុងគុកវិញ ។

វណ្ណៈ នៅពេលណាទើបមានការចាប់ខ្លួនយកទៅដើងឯក?

ខន ទាល់តែគេយកចម្លើយអស់ ចំរាញ់អស់ហើយបានគេមានថ្ងៃមួយដែលគេត្រូវប្រមូលផ្តុំអ្នក ទោសដែលយកចម្លើយអស់ អាណឹងនៅលើអ្នកការពារ ពីព្រោះខ្ញុំដឹងតែពីសួររួចហើយ យកមកដាក់នៅក្នុងគុកវិញ ។

វណ្ណៈ ខ្ញុំចង់សួរពួតីវិធីសួរអ្នកទោស ។ ដំបូងឡើយគេធ្វើយ៉ាងម៉េចពេលដែលចាប់អ្នកទោសមក? នៅពេលចាប់ផ្តើមសួរត្រូវធ្វើយ៉ាងម៉េច?

ខន នៅពេលចាប់ផ្តើមសួរ គេយកអ្នកទោសទៅដាក់ច្រវាក់ ដាក់ខ្នោះឲ្យជាប់ដៃ ឲ្យអង្គុយនៅ លើកៅអី ។

វណ្ណៈ ប៉ុន្តែពេលហ្នឹងអ្នកទោសត្រូវថតរូប ធ្វើប្រវត្តិរូបរួចហើយទើបយកមកសួរឬក៏យ៉ាងម៉េច?

ខន អាណឹងការងារគេផ្សេង ខ្ញុំដឹងតែយកទៅសួរពីប្រវត្តិរូប បងប្អូន ឪពុកម្តាយ ។ មុននឹងធ្វើ ទារុណកម្ម ជួនកាលសួរ១០ថៃទៅកន្លះខែ ។ អង្គុយនិយាយគ្នា សួររបៀបធ្វើនយោបាយ ដល់តែយូរទើបយើងរាយការណ៍ឲ្យគេ ដូចថាឈ្មោះ“ក” ដែលយកមកសួរមិនទាន់បាន ចម្លើយ មិនទាន់សារភាពទេ ចឹងខាងលើឲ្យយោបល់យ៉ាងម៉េច? ចឹងគេឲ្យធ្វើទារុណកម្ម ។ ប៉ុន្តែខ្ញុំភាគច្រើន ខ្ញុំសួរអ្នកទោសដែលគេធ្វើទារុណកម្មរួចហើយ ព្រោះខ្ញុំនៅក្រុមអង្កាមគេ វាយបែកខ្នងបែកឈាមពេញទាំង យកម៉ាសុទ្ធតែអ្នកមានដំបៅស្អុយ ។ ជួនកាលគ្រាន់តែ យកដៃប៉ះដំបៅ ក៏ស្រែឈឺចង់ស្លាប់ហើយ ។

វណ្ណៈ ក្រុមអន្លង់ជាក្រុមបន្តពីក្រុមណាមួយ?

ខន វាមានបីក្រុមៈ ក្រុមគ្រជាក់ដែលហៅថាក្រុមស្លូត... ក្រុមស្លូត ក្រុមក្ដៅ ក្រុមអន្លង់ ។

វណ្ណៈ ក្រុមស្លូតធ្វើរបៀបម៉េច?

ខន ស្លូតគេធ្វើមុន ដូចដែលខ្ញុំនិយាយប្រាប់ យើងយកមកធ្វើនយោបាយ ។ បើសួរមិនចេញ ៨,១០ថ្ងៃ យើងបញ្ជូនទៅឲ្យក្រុមក្ដៅ ។ ទៅដល់ក្រុមក្ដៅគេដាក់ខ្នោសជាស់ៗ បែកឈាមដាបចីងទៅ ។ បើកាលចេញក៏ចេញ បើអ្នកណាមិនចេញអាណឹងគេរុញចោលនៅក្នុងគុកវិញ ហើយគេបញ្ជូនឈ្មោះមកឲ្យក្រុមអន្លង់វិញ ។ ក្រុមអន្លង់គេយកមកច្រើនតែអ្នកមានដំបៅ ។

វណ្ណៈ ក្រុមអន្លង់ប្រើវិធីដូចក្រុមស្លូតដែរឬក៏យ៉ាងម៉េច?

ខន អាណឹងក្ដៅផងត្រជាក់ផង ប៉ុន្តែគ្រាន់ថា ក្រុមអន្លង់វាឃូរកុំរ៉ៃ សួរទាល់តែអស់ចិត្ត អាណាចេញក៏ចេញ អាណាមិនចេញក៏ទុកចោល រាប់ខែរាបល់ឆ្នាំ ។

វណ្ណៈ អ្នកទោសណឹងចាំបាច់ណាស់បានគេយកមកក្រុមអន្លង់ ឬក៏យ៉ាងម៉េច?

ខន អានេះវាមិនជាចាំបាច់ទេ សំខាន់សួរឲ្យវាឆ្លើយតែម្ដង ព្រោះខ្ញុំសួរក៏មិនមានអ្នកធំៗដែរ ត្រឹមកងវរយ យុទ្ធជន ប្រធានភូមិ ប្រធានសហករណ៍ ។ តាមមើលទៅវាមិនសំខាន់ប៉ុន្មានទេ ការចង់បានរបស់គេគឺចម្លើយ ។

វណ្ណៈ ការដែលយកអ្នកទោសម្នាក់ៗយកទៅសួរ អាណឹងជាការងារដែលពូត្រូវតែធ្វើ ឬក៏មានបញ្ជាមក?

ខន គេបញ្ជា គេឲ្យឈ្មោះហ្នឹង ។ ពេលដែលយើងធ្វើចប់មួយវគ្គ គេឲ្យឈ្មោះមួយទៀតមក ហើយយើងមកសួរបងធី ថាអ្នកទោសនៅបន្ទប់ណាៗ បងធីរកឈ្មោះឲ្យថានៅបន្ទប់ណា ។

វណ្ណៈ ក្នុងមួយថ្ងៃពូសួរអ្នកទោសតែម្នាក់ ឬក៏សួរច្រើននាក់?

ខន សួរតែម្នាក់ទេ ។ ម្នាក់ណឹងមិនមានសួរតែមួយថ្ងៃទេ សួររាប់ខែ ខ្លះក៏ឆាប់ទៅ១ខែ ពីរខែ បីខែ បួនខែក៏មានដែរ ។

វណ្ណៈ ចម្លើយសារភាព ពេលខ្លះអ្នកទោសសរសេរ ឬក៏ពូសរសេរ?

ខន ប្រសិនបើអ្នកទោសនោះចេះអក្សរ អ្នកទោសជាអ្នកសរសេរ ។ បើអ្នកទោសមិនចេះអក្សរ យើងសួរ អ្នកទោសនិយាយមកយើងសរសេរ ។

វណ្ណៈ ខ្ញុំឃើញចម្លើយខ្លះមានការផ្ទៀងផ្ទាត់ ចុះហត្ថលេខា ហើយមានឈ្មោះអ្នកសួរចម្លើយថែមទៀត អាណឹងវាចាំបាច់យ៉ាងម៉េច?

ខន អាណឹងឲ្យអ្នកទោសទទួលខុសត្រូវរឿងសកម្មភាពរបស់គេ ហើយយើងអ្នកសួរក៏ត្រូវចុះឈ្មោះឲ្យគេ ដើម្បីដឹងថា អ្នកណាសួរចំពោះឯកសារណឹង ។

វណ្ណៈ ពូធ្លាប់សួរអ្នកមកពីអង្គភាពជាមួយគ្នាដែរ?

ខន ដូចជាមិនចាំទេ ។

វណ្ណៈ បើតាមខ្ញុំមើលឯកសារ ខ្ញុំមានឃើញម្នាក់មកពីអង្គភាព៧០៣ ។ ពេលដែលពូសួរ ពូមានដែលគិតថាអ្នកនេះគ្នាឯង គ្នាគេដែរ?

ខន អារម្មណ៍គឺគិតហើយ ប៉ុន្តែចម្លើយដែលខ្វាំងឲ្យម៉ោមិនឲ្យបាត់របស់គេមួយម៉ាត់ទេ ព្រោះខ្លាចជាប់រឿងដល់ខ្លួនទៀត ។ សូម្បីតែឪពុកម្តាយឯងត្រូវខ្មាំងឆ្លើយដាក់ក៏អត់ហ៊ានបំបាត់ចម្លើយគេដែរ ។

វណ្ណៈ មានករណីណាមួយដែលពូសួរ ហើយគេឆ្លើយថាបានរួមសកម្មភាពជាមួយពូដែរ?

ខន អត់ដែលមានទេ ។

វណ្ណៈ ពូមានធ្លាប់បារម្មណ៍ខ្លាចអ្នកទោសឆ្លើយដាក់ពូដែរ?

ខន អារម្មណ៍មានគិតជាប់រាល់ថ្ងៃ ។ បារម្ភបំផុតអ្នកនៅជាមួយគ្នានៅក្នុងអង្គភាពសួរ ។ ចិត្ត១នឹកឃើញថា មិនដឹងអ្នកណាឆ្លើយដាក់ មិនដឹងថ្ងៃណា នឹកឃើញអញ្ចឹង ។ ហើយមកឥឡូវខ្ញុំមើលឯកសារអ្នកដែលគេចាប់មានមែន ។ ប៉ុន្តែគ្រាន់តែខ្ញុំមើលនៅក្នុងបញ្ជីរបស់ ចាន់ និង ឌុច គេថា "កសាងសិន, ទុកចាំមើលសិន" ។

វណ្ណៈ ចាន់នៅប្រចាំការនៅទីនេះ ឬក៏មានផ្ទះនៅផ្សេងទៀត?

ខន ចាន់ ផ្ទះនៅជាមួយ ឌុច ។ មិនមែននៅទីនេះទេ ចេញចូលៗ ។

ហួ នៅប្រចាំទីនេះគឺ ហ៊ី ប្រធានការពារ ។ អ្នកការពារគឺនៅតែការពារ ជាន់លើ ជាន់កណ្តាល ជាន់ក្រោម ទៅតាមក្រុម ។

វណ្ណៈ បើតាមខ្ញុំមើលឯកសារ ខាង៧០៣ភាគច្រើននៅខាងចាប់ ខាងការពារជាមួយ ហ៊ី ហើយពួកនៅបស្ទឹមច្រើននៅខាងសួរជាមួយ ឌុច?

ខន អាណឹងម៉ោក្រោយទេ ទាល់តែអស់កម្លាំង៧០៣ហើយ បានពួកណឹងចូលទៅសួរ ។ បើមិន

ជឿខ្ញុំសួរអ្នកអស់នេះទៅដឹងហើយ ។

ហូ អស់៧០៣ហើយ ។ ដំបូងតាណាតកងពល៧០៣ ដល់តែគេចាប់តាណាម៉ោ គេឆ្លើយដាក់មេ មេឆ្លើយដាក់កូន ហើយបានគេស្រាវជ្រាវបន្តនៅក្នុងណឹង ។

វណ្ណៈ ខ្ញុំមើលចម្លើយតាណាត ប្រហែលជាគាត់សរសេរនៅថ្ងៃ២៥ ខែ១២ ឆ្នាំ៧៨ កៀកបែកមែនទែនហើយ ប៉ុន្តែខ្ញុំមិនដឹងថា គាត់ណឹងគេចាប់ខ្ញុំខ្លួននៅក្នុងកំឡុងខែហ្នឹងឬក៏យូរហើយ? គេចាប់គាត់នៅក្នុងឆ្នាំ៧៧ ឬក៏យ៉ាងម៉េច?

ខន មិនដឹងទេ ខ្ញុំក៏អត់ដឹងថា គេចាប់ តាណាត យកមកដាក់នៅណឹងដែរ ប៉ុន្តែខ្ញុំដឹងតាមរយៈអញ្ចេះ ឧទាហរណ៍ថា ខ្ញុំសួរខ្មាំងម្នាក់មកពីខាងក្រៅ ថាតាណាតគេចាប់ហើយ ខ្ញុំដឹងចឹងបើថាដឹងនៅក្នុងនេះតែម្តង ខ្ញុំមិនដឹងទេ ។

វណ្ណៈ ជាទូទៅកម្មាភិបាលធំដូច តាណាត គេដាក់នៅក្នុងណឹងដែរ?

ខន មិនដឹងថានៅត្រង់ណា ខ្ញុំសង្ស័យតែនៅគុកពិសេសខាងត្បូង អត់មានទេនៅក្នុងនេះ ។

វណ្ណៈ ពូធី ដែលនៅក្តាប់ឯកសារ តាណាត មានចូលទីនេះដែរទេ ពូមានចុះឈ្មោះទេ?

ធី តាណាត កាលណឹងគេអត់ឲ្យខ្ញុំចុះទេ ព្រោះគេយកចូលទៅបន្ទប់ពិសេសតែម្តង អ្នកធំៗគេដឹងរួចហើយ គេមិនឲ្យយើងធ្វើទេ ។ បើខ្ញុំមានវៃឈ្មោះគឺ ហ៊ា អ្នកឲ្យខ្ញុំធ្វើ ។

ហូ ព្រោះអាកន្លែងគុកនេះ(ទួលស្លែង) គេដាក់តែអ្នកទោសតូច អ្នកធំៗគេដាក់នៅគុកពិសេសនៅផ្ទះខាងត្បូងថ្នល់នេះ ។ គុកពិសេសសម្រាប់គេក្រុមក្តៅ ក្រុមពិសេសដែលគេយាមនៅណឹង ។

វណ្ណៈ ហ៊ា ក្តាប់ទាំងក្រុមពិសេសណឹងដែរ?

ខន ក្តាប់រួមទាំងអស់ (ខន ហូ និង ធី ឆ្លើយស្របគ្នា) ។ ខ្ញុំអ្នកសួរមិនដែលហ៊ានឈានជើងទៅកន្លែងពិសេសណឹងផងទេ ។ ហ៊ា គេអាចចេញចូលបាន ។

វណ្ណៈ ខ្ញុំមិនច្បាស់ថា ស-២១កើតឡើងនៅកន្លែងណឹង ឬក៏នៅកន្លែងណាមួយមុន?

ធី មុនដំបូងវានៅកន្លែង ប៉េ-ហ្ស៊ី ស្នងការដ្ឋាននគរបាលជាតិរាជធានីភ្នំពេញ ហើយបានគេរើមកទីនេះ ។

វណ្ណៈ យ៉ាងម៉េចបានផ្លាស់មកនេះ?

ធី ខ្ញុំមិនដឹងដែរ ប៉ុន្តែដំបូងនៅទីនោះទេ ក្រោយមកបានមកទីនេះ ។

វណ្ណៈ ឌុច គ្រប់គាំងពីនៅខាងនោះ ឬក៏យ៉ាងម៉េច?

ខន ឌុច គ្រប់គ្រងគាំងពីនោះម៉ោ ។ កាលមុន តាណាត ទេ ខ្ញុំមិនដែលឃើញ ឌុចទេ ។ ប៉ុន្តែដល់ ឌុច ម៉ោបានដក តាណាត ចេញ ពីព្រោះពេលដែលខ្ញុំធ្វើបញ្ជី ស-២១មិនមែនដាក់នៅក្រោមចំណុះរបស់ខាងណាទេ ដាក់របស់៧០៣តែម្តង ពីព្រោះដំបូងស្ថិតក្រោមការក្តោបក្តាប់របស់៧០៣ មិនមែនរបស់អង្គភាពណាទេ ទាល់តែ ឌុច មកដល់បានផ្តាច់ទៅជាស-២១ ។

វណ្ណៈ ចឹងដំបូងគុកណឹងស្ថិតនៅក្រោមចំណុះ៧០៣?

ធី អាណឹង តាណាត ក្តោបក្តាបពេលដែលនៅ ប៉េ-ហ្ស៊ី ។

វណ្ណៈ ៧០៣ ក្តោបក្តាប់គុកបានយូរទេ?

ធី ត្រឹម តាណាត ក្តោបក្តាប់មិនយូរទេ បន្ទាប់ពី ឌុច ទៅនៅជាមួយ២,៣ខែ ក៏ផ្លាស់មកនៅទីនេះ ។

ខន កាលណឹងនៅកន្លែងនោះមិនទាន់មានទ្រង់ទ្រាយធំទេ ។

ធី មិនទាន់មានទ្រង់ទ្រាយធំទេ មិនទាន់មានធ្វើទារុណកម្ម មិនទាន់សួរចម្លើយទេ ។

វណ្ណៈ ពេលចាប់សួរខ្លាំងក្លា ចាប់ពីពេលណាមក?

ខន ៧៧,៧៨អីណឹង ។

វណ្ណៈ បើតាមខ្ញុំមើលចម្លើយសារភាព អ្នកដែលធ្វើការនៅស-២១ភាគច្រើនចាន់នៅខែ៧ ខែ៨ ឆ្នាំ៧៧ មានការចាប់ច្រើន?

ខន ចាប់ពីចុង៧៦ ឆ្នាំ៧៧ មានការចាប់ច្រើន ។

វណ្ណៈ ខ្ញុំឃើញពូសួរជនជាតិភាគតិចម្នាក់ឈ្មោះ ឡាយ ក្លឹង ពូមាននឹកឃើញឡើងវិញទេ?

ខន អត់មានចាំទេ ខ្ញុំដូចមិនបានកត់ទុកក្នុងខួរក្បាលទេ អត់មាននឹកឃើញ ។

វណ្ណៈ ដូចថា ពូមានសួរករណីអ្នកទោសម្នាក់ ហើយឈានទៅដល់ការធ្វើទារុណកម្ម ទាល់តែមានលក្ខខ័ណ្ឌបែបណាទើបពូធ្វើទារុណកម្ម ទៅវៃចំពោះអ្នកណឹង?

ខន អាណឹងនៅពេលដែលយើងសួរអ្នកណឹងមិនព្រមឆ្លើយ ខាងលើគេដាក់បញ្ជាឲ្យធ្វើទារុណកម្ម បើយើងមិនធ្វើ យើងមានឈ្មោះថា ប្រឆាំងនឹងបញ្ជាគេ យើងត្រូវតែធ្វើ ក្នុងលក្ខណៈណាក៏ដោយ ។

វណ្ណៈ ពូធ្វើណឹងក្នុងលក្ខណៈជាកាតព្វកិច្ច និងក៏ពូធ្វើដោយថា សួរមិនបានចម្លើយ?

ខន អាណឹងជាកាតព្វកិច្ចដាច់ខាតមកពីថ្នាក់លើ ត្រូវតែធ្វើ ប៉ុន្តែធ្វើទារុណកម្មមិនឲ្យស្លាប់ ។

វណ្ណៈ ខ្ញុំចង់សួររឿងទូទៅមួយចំពោះពូទាំងអស់ ។ ការមុនមានកងវរសេនាតូចមួយរបស់៧០៣ ដែលនៅក្រោមការក្តោបក្តាប់របស់ ហ៊ី គឺ១៨៣ ។ បន្ទាប់មកតម្លើងទៅជា៧០៤ ដែលមាន ប៉េងឡេង , ហ៊ី នៅក្រាំងយ៉ូវ?

ហូ អាណឹងកាលនៅក្នុងសង្គ្រាម ។ ហ៊ី កន្ទុញគ្នាឡើងក្រោមៗមក បើតាមពិតទៅគេចាប់មួយចំនួនមកហើយ ។

វណ្ណៈ នៅក្នុងសង្គ្រាមខាង៧០៤មានតួនាទីវៃពិសេស ស៊ើបការណ៍ ។ ប៉ុន្តែនៅក្នុងភ្នំពេញ ពួកណឹងមានតួនាទីចាប់ចងអ្នកទោស មានការទាក់ទងជាមួយស-២១ដែរទេ? ពីព្រោះអ្នកធ្វើការនៅស-២១ភាគច្រើនបានជ្រើសរើសចេញពីណឹង?

ខន ការងារខាងក្រៅទេអាណឹង ។

វណ្ណៈ ទាហានអាចទាក់ទងជាមួយស-២១ដែរទេ?

ខន អត់ឲ្យដឹងទេ ។

ហូ ដូចឧបមាខ្ញុំជម្រាបប្អូន ខ្ញុំកងការពារដឹងតែពីការពារ ហើយអត់មានដើរចេញបានទេ ។ ដល់ពេលដែលគេមកដូរ យើងត្រូវផ្អែកឆេរហើយបានយើងទៅហូបបាយ ។

វណ្ណៈ រោងបាយនៅកន្លែងណា?

ហូ នៅខាងជ្រុងខាងកើត ។ ហូបបាយហើយដេក ។ ដល់តែម៉ោង៦ ខ្ញុំមកដូរគេវិញ ។

ខន ៧០៤ ជាកម្លាំងពិសេសរបស់៧០៣ ទេ មិនមែនទាក់ទងនៅខាងនេះទេ ហើយរឿងថាពាក់ព័ន្ធ ឬមិនពាក់ព័ន្ធយើងអត់មានដឹងទេ ពីព្រោះយើងនៅកន្លែងនេះអត់មានដឹងរឿងអីនៅខាងក្រៅទេ ។

ហូ ហើយបើយើងជួបគ្នាក៏អត់មានហ៊ាននិយាយទេ ។

វណ្ណៈ កងពល១២ ក្រោយមកជា៧០៣ កាលដែលនៅតំបន់២៥មានឈ្មោះ តាសុក កាន់កាប់ដែរឬក៏យ៉ាងម៉េច?

ធី មានតែ តាណាត តាពីន ។ តាសុក នៅសេនាធិការតំបន់២៥ ។

វណ្ណៈ នៅក្រោមឆ្នាំ៧៥មានពូថា គ្រោងធ្វើរដ្ឋប្រហារ ហើយក៏មានការចាប់ខ្លួន តាជ័យ នងសួន

សុខប៊ុតចំរើន អាណឹងយ៉ាងម៉េចដែរ?

ខន ខ្ញុំមិនដែរ ។

វណ្ណៈ ពូនិយាយថា ពេលដែលពូនិយាយរឿងរាវឡើងវិញ ពូមានអារម្មណ៍ខ្មាសអៀនខ្លួនឯង ។ ប៉ុន្តែការដែលពូនិយាយ អតីតកាលពូមានអារម្មណ៍ធូរស្រាល ឬក៏គៀបសង្កត់អារម្មណ៍ពូខ្លាំងឡើង?

ខន ឥឡូវអត់មានបញ្ហា ខ្ញុំលែងគិតច្រើន ស្រុកគេដល់នេះហើយ ទៅយ៉ាងម៉េចក៏ទៅ ខ្ញុំអត់មានគិតគូអីទៀតទេ បើបាននិយាយប្រាប់គេអស់ហើយ ខ្ញុំដឹងរឿងអីខ្ញុំនិយាយប្រាប់ ខ្ញុំបានធ្វើអីនិយាយប្រាប់ ។

វណ្ណៈ នៅទីនេះក្រៅពី ឌុច ហើយធំជាង ឌុច មានអ្នកណាមកមើលចូលមកមើលដែរ?

ខន សុន សេន ។ សុន សេន ចូលមកមើល ចូលមកបង្រៀនណែនាំនៅសាលាខាងក្រៅ ។

វណ្ណៈ គេមានកំណត់ពេលវេលាយ៉ាងម៉េចដែរ?

ធី អត់មានទេ មកតែ២,៣ថ្ងៃក៏លែងឃើញ ។

វណ្ណៈ ក្នុងឆ្នាំណាដែលគាត់ម៉ោ?

ខន ប្រហែលជាឆ្នាំ៧៧ ។

វណ្ណៈ គាត់មកបង្រៀនទូទៅឬក៏យ៉ាងម៉េច?

ខន ស-២១ទាំងអស់ បង្រៀនជាទូទៅ ។

វណ្ណៈ ក្រៅពី សុន សេន មានអ្នកទៀតមកដែរ?

ខន មិនដែលឃើញទេ ។

វណ្ណៈ នៅពេលដែលពូពួកមេខ្មែរក្រហមទាំងអស់និយាយថា មិនបានដឹងក្តីពីការសម្លាប់មនុស្ស តើពូគិតថាយ៉ាងម៉េច?

ខន ឆេវ ។

ហូ ឆេវ, បើនិយាយចង់តែទៅចូលផ្ទាល់ ។

ខន ហ៊ីបើចង់ឲ្យខ្ញុំទៅធ្វើសាក្សី ខ្ញុំត្រៀមខ្លួនទៅ១០០ភាគរយចាំមុន ពេលណាក៏ដោយ ។

ហូ តាំងពី ខៀវ សំផន និងអ្នកទោសល់ ខ្ញុំសួរថា បើអស់លោកទាំងអស់ណឹងថាអត់ដឹងគុកទួលស្លែង បើអស់លោកមិនដឹង តើគុកទួលស្លែងអ្នកណាបង្កើត? ឬមួយពួកខ្ញុំដែលអ្នកតូច

តាចបង្កើតគុក? ហើយនៅក្នុងសម័យខ្មែរក្រហម ប្រទេសកម្ពុជាទាំងមូលកើតសង្គ្រាម តើអ្នកណាដែលដឹកនាំឲ្យធ្វើសង្គ្រាម? មានតែអស់លោកមេខ្មែរក្រហមទាំងអស់ណឹងដែលជាអ្នកបង្កើតឲ្យធ្វើសង្គ្រាម ហើយកុំនិយាយថា អស់លោកទាំងអស់មិនដឹងនោះ គឺដឹង ប៉ុន្តែចង់លុបលាងកំហុសរបស់ខ្លួន ហើយទម្លាក់កំហុសមកលើអ្នកតូចតាចវង់គ្រោះ ។

ខន ខ្ញុំបាននិយាយនៅក្នុងឯកសារទាំងអស់រួចហើយ ខ្ញុំបានទទួលស្គាល់ទាំងអស់ចំពោះអំពើដែលខ្ញុំបានធ្វើ ប៉ុន្តែចំពោះមេដឹកនាំនៅក្នុងគណៈមជ្ឈិមបក្សទាំងអស់ ដែលដឹកនាំបង្គាប់បញ្ជាឲ្យខ្ញុំធ្វើ ហើយមិនទទួលខ្លួនថា ជាអ្នកដឹងព្ធ ចឹងមានតែអ្នកណឹងភ្លើ បានជាកាន់កាប់រដ្ឋអំណាចប៉ុន្មានឆ្នាំហើយឆ្លើយថាមិនដឹង បង្កើតទួលស្លែងជិតមួយគីឡូប៉ូនជ្រុង ហើយមិនដឹងខ្យល់អីសោះ ខ្ញុំមាននិយាយនៅក្នុងឯកសារ ។

វណ្ណៈ បើសិនជាគំនិតរបស់ពូ តើគួធ្វើយ៉ាងម៉េចដើម្បីឲ្យអ្នកទាំងអស់ណឹងលែងមានឱកាសនិយាយថា ខ្លួនអត់ដឹង?

ខន អាណឹងវាអញ្ចឹងហើយ ឧទាហរណ៍ថាបើសិនជាខ្ញុំជាប់គុក ក៏ខ្ញុំមិនឲ្យអ្នកទាំងអស់ណឹងដេកស្រួលដែរ ខ្ញុំនិយាយត្រង់ចឹងហ្មង ស្រណុកស្លាប់ ។ ខ្ញុំគិតយូរហើយ ខ្ញុំឈឺចាប់ណាស់ ។ ខ្ញុំធ្វើបាប ធ្វើទោសគេមែន តែក៏ត្រូវគិតពីយុត្តិធម៌ដែរ ។ តាំងពីនេះម៉ោ ខ្ញុំមិនដែលភ័យព្រួយបារម្ភខ្លាំងទេ មានចិត្តតូចវាមានមែន កាលជិនាន់នោះខ្ញុំដេកញាក់ ៕

បញ្ជាក់ៈ

១- សួស ធី អតីតជាកម្មាភិបាលផ្នែកកាន់បញ្ជីអ្នកទោសនៅមន្ទីរស-២១

២- ញ៉ែប ហូ អតីតយុទ្ធជនកងការពារអ្នកទោសនៅមន្ទីរស-២១ និង ត្រូវជាបងរបស់ សុខ ប៉េង ប្រធានកងរយផ្នែកការពារអ្នកទោសនៅស-២១

ចប់